**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :............០៣៦/១៤...........ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់ឯកសណ្ឋានរបស់អធិការការងារតែមួយ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមតម្រូវការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១.- គោលបំណង**

ត្រូវបានបង្កើតឯកសណ្ឋានរបស់អធិការការងារតែមួយ ដើម្បីប្រើប្រាស់សម្រាប់បំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ២.- អំពីឯកសណ្ឋាន**

ឯកសណ្ឋានរបស់អធិការការងារតែមួយត្រូវកំណត់ដូចខាងក្រោម ៖

- អាវសឺមិស៍ដៃខ្លី ពណ៌ត្រាវចាស់ កឧប គ្រែស្មាពីរសងខាង ហោប៉ៅពីរមានគម្របស្លឹកពោធិ៍
- សម្រាប់បុរសខោជើងវែងពណ៌ដូចអាវ មានហោប៉ៅក្រោយមួយ មានគម្របហើយដេរបង្កប់ និងមានហោប៉ៅចំហៀងពីរ
- សម្រាប់នារី សំពត់ហ្ស៊ីបពណ៌ដូចអាវ កាត់សម្រុងក្រោមជង្គង់នែកពីក្រោយ ០.៥ សង់ទីម៉ែត្រ
- ស្បែកជើងពណ៌ខ្មៅ និងមានស្រោមជើង
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ និងក្បាលពណ៌ទឹកមាស
- មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ នៅជើងមួកមានរំព័ទ្ធដោយក្រណាត់កាម្វីពណ៌ខ្មៅ និងមានរបាំងជ័រពណ៌ខ្មៅនៅខាងមុខ។

រូបគំនូរឯកសណ្ឋានសម្រាប់បុរស និងនារី របស់អធិការការងារតែមួយ ដូចមានគំរូក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃប្រកាសនេះ។

**ប្រការ ៣.- អំពីសញ្ញាសំគាល់**

**ក.សញ្ញាសំគាល់សម្រាប់ថ្នាក់អគ្គនាយក នាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត**

❖ ***មួកកាស្កេតៈ***

- ចំពីមុខផ្នែកខាងលើនៃមួក មានសញ្ញាព្រះសង្ហារពណ៌ទឹកមាស
- នៅជើងមួកផ្នែកខាងមុខមានវ័ណ្ឌភ្ជី និងមានឡេវរូបព្រះសង្ហារពណ៌ទឹកមាសនៅចុងសងខាងវ័ណ្ឌ
- នៅលើហាមមួកមានប៉ាក់ក្បាច់ភ្ញីទេសឌិនដល់ជើងមួកពណ៌ទឹកមាស។

❖ ***បន្ទះនៅលើស្មាៈ***

- ធ្វើពីក្រណាត់កាម្វីពណ៌ខៀវចាស់
- ផ្នែកកណ្តាលមានរូបសញ្ញាម្កុដរាជ និងផ្នែកខាងក្រោមម្កុដរាជមានឆ្លាក់អក្សរ "ក.ប" ពណ៌ទឹកមាស
- នៅផ្នែកខាងក្រោមអក្សរ "ក.ប" មានភ្ញីរាងត្រីកោណពីឈមគ្នាពណ៌ទឹកមាស
- ចំពោះថ្នាក់អគ្គនាយក មានវ័ណ្ឌពណ៌ទឹកមាសព័ទ្ធជុំវិញដែលមានបីជុំ
- ចំពោះថ្នាក់នាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត មានបីជុំ ប៉ុន្តែវ័ណ្ឌទីបីខាងក្នុងមានលក្ខណៈដាច់ៗ។

❖ ***រូបសញ្ញាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖*** នៅដៃអាវខាងស្តាំផ្នែកខាងលើឃ្លាតពីស្មា ១០ (ដប់) សង់ទីម៉ែត្រ។

❖ ***ស្លាកឈ្មោះ៖*** មានឈ្មោះ អត្តលេខ និងតួនាទី ធ្វើអំពីជ័ររឹងភ្លឺ ពណ៌ខៀវចាស់ អក្សរពណ៌ទឹកមាស ពាក់លើហោប៉ៅអាវខាងឆ្វេង។



ស្ន

**ខ.សញ្ញាសំគាល់សម្រាប់ថ្នាក់ប្រធាន អនុប្រធានការិយាល័យ ថ្នាក់កណ្តាល និងប្រធានការិយាល័យមន្ទីររាជធានី-ខេត្ត**

សញ្ញាសំគាល់មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់អគ្គនាយក ថ្នាក់នាយកដ្ឋាន និងថ្នាក់មន្ទីររាជធានី-ខេត្ត ប៉ុន្តែខុសគ្នាត្រង់៖

- ចំពោះប្រធានការិយាល័យថ្នាក់កណ្តាល បន្ទះនៅលើស្មាមានវណ្ឌពណ៌ទឹកមាសព័ទ្ធពីរជុំ
- ចំពោះអនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យរាជធានី ខេត្ត បន្ទះលើស្មាមានវ័ណ្ឌពីរជុំ ប៉ុន្តែវ័ណ្ឌទីពីរខាងក្នុងមានលក្ខណៈដាច់ៗ។

**គ.សញ្ញាសំគាល់សម្រាប់អនុប្រធានការិយល័យមន្ទីររាជធានី-ខេត្ត និងមន្ត្រី**

សញ្ញាសំគាល់មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់អគ្គនាយក ថ្នាក់នាយកដ្ឋាន មន្ទីររាជធានី-ខេត្ត ប្រធានការិយាល័យ អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យរាជធានី-ខេត្ត ប៉ុន្តែខុសគ្នាត្រង់ បន្ទះនៅលើស្មា មានវ័ណ្ឌពណ៌ទឹកមាសព័ទ្ធមួយជុំ ។

រូបគំនូសញ្ញាសក្តសំគាល់របស់អធិការការងារតែមួយ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ ។

**ប្រការ ៤.- របបផ្គត់ផ្គង់**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុកផ្គត់ផ្គង់ជូនអធិការការងារតែមួយនូវឯកសណ្ឋាន ដែលបានកំណត់ខាងលើនេះ។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធានទីភ្នាក់ងារ ជាតិមុខរបរ និងការងារ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

  «ដើម្បីជូនជ្រាប»
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត

  «ដើម្បីជូនជ្រាប និងអនុវត្ត»
- កាលប្បវត្ត-ឯកសារ



ល

# ឧបសម្ព័ន្ធទី ០១



## ឧបសម្ព័ន្ធទី ០២



# ឧបសម្ព័ន្ធទី ០៣




អគ្គនាយក




នាយកដ្ឋាន




ប្រធានការិយាល័យ
ថ្នាក់កណ្ដាល




អនុប្រធានការិយាល័យ
ថ្នាក់កណ្ដាល
និង ប្រធានការិយាល័យ
មន្ទីរ រាជធានី - ខេត្ត




មន្ត្រីថ្នាក់កណ្ដាល
និង អនុប្រធានការិយាល័យ
មន្ទីរ រាជធានី - ខេត្ត